**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

លេខ ៦៥៧ បទ

# សេចក្តីបំភ្លឺ
# ទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពី
# ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT)

រយៈពេលចុងក្រោយនេះ មានការពិភាក្សា ការសួរដេញដោល និងការធ្វើប្រតិកម្មជាច្រើន ជុំវិញសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន រហូតនាំដល់ការបញ្ចេញការព្រួយបារម្ភពាក់ព័ន្ធនឹងការគំរាមកំហែងចំពោះសេរីភាពក្នុងការបញ្ចេញមតិលើប្រព័ន្ធអ៊ីនធឺណិត។

ដោយទិដ្ឋភាពខ្លះនៃសេចក្តីព្រាងច្បាប់នេះ ពាក់ព័ន្ធនឹងអាណត្តិរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នោះ ក្រសួងសូមធ្វើការបំភ្លឺជូនសាធារណៈជនទូទៅបានជ្រាបដូចខាងក្រោមនេះ ៖

**១-ការព្រាងច្បាប់នេះស្ថិតនៅក្នុងដំណាក់កាលជាការផ្តុំឯកសារបញ្ចូលគ្នានៅឡើយ។**

នៅពាក់កណ្តាលឆ្នាំ២០១០ ទីស្តីការគណៈរដ្ឋមន្ត្រី បានបង្កើតក្រុមការងារមួយ ដើម្បីបំពេញការងារតាក់តែងសេចក្តីព្រាងច្បាប់នេះ ដោយមានអ្នកជំនាញការខាងច្បាប់ឧក្រិដ្ឋកម្មតាមបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ពីក្រុមប្រឹក្សាអឺរ៉ុប គឺលោក Alexander Seger ប្រធានផ្នែកឧក្រិដ្ឋកម្មសេដ្ឋកិច្ច ចូលរួមសហការ។ ការតាក់តែងព្រាងច្បាប់នេះ ក៏មានការសហការពីប្រទេសមួយចំនួនក្នុងតំបន់តួយ៉ាងប្រទេសថៃ ឥណ្ឌូណេស៊ី ហ្វីលីពីន អូស្ត្រាលី និងណូវែលហ្សេឡង់។ សិក្ខាសាលាមួយត្រូវបានរៀបចំឡើងជាលក្ខណៈអន្តរក្រសួង ក្រោមប្រធានបទ "**ការយល់ដឹងអំពីការតាក់តែងច្បាប់តាមប្រព័ន្ធបច្ចេកវិទ្យា**"។ យ៉ាងណាក៏ដោយ ដំណើរការព្រាងច្បាប់នេះ ទើបតែបានចងក្រងឡើងដោយប្រមូលនូវឯកសារពាក់ព័ន្ធនានា ដាក់បញ្ចូលគ្នា និងបានធ្វើការពិភាក្សាខ្លះៗ ក្នុងកំរិតការងារបច្ចេកទេសតែប៉ុណ្ណោះ។

ក្រោយមក សេចក្តីព្រាងច្បាប់នេះ ក៏ត្រូវបានទុកមួយអន្លើសិន ដោយសាររាជរដ្ឋាភិបាលបានប្រមូលផ្តុំកិច្ចប្រឹងប្រែងដើម្បីពិនិត្យច្បាប់ ឯកសារគតិយុត្តិ ក៏ដូចជាជាប់ដោះស្រាយការងារនានាដែលមានលក្ខណៈបន្ទាន់ និងអាទិភាពជាង។

**២-ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ពាក់ព័ន្ធនឹងវិស័យ និងសមត្ថកិច្ចជាច្រើន។**

តាមស្មារតីនៃការព្រាងពីដំបូងឡើយ ច្បាប់នេះមានគោលបំណងកំណត់វិធានការអប់រំ បង្ការទប់ស្កាត់ និងបង្ក្រាបការប្រព្រឹត្តបទល្មើសនានាតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីធានាការអនុវត្តច្បាប់ ប្រយុទ្ធប្រឆាំង និងបង្ក្រាបបទល្មើសតាមប្រព័ន្ធ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក៏ដូចជាធានាសុវត្ថិភាព និងការពារផលប្រយោជន៍ស្របច្បាប់ក្នុងការប្រើប្រាស់ និងអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ឧក្រិដ្ឋកម្ម និងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានច្រើនប្រភេទ ហើយពាក់ព័ន្ធនឹងសមត្ថកិច្ចជាច្រើន រាប់ពីការភ្ជាប់ដោយខុសច្បាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័រអ្នកដទៃ ការជ្រៀតជ្រែកទិន្នន័យ-ប្រព័ន្ធការផលិតចែកចាយរូបអាសអាភាសកុមារ ការឆបោក ការក្លែងបន្លំតាមរយៈកុំព្យូទ័រ ក៏ដូចជាបទល្មើសផ្សេងទៀតដែលប៉ះពាល់ដល់ឯករាជ្យ អធិបតេយ្យភាព សន្តិសុខជាតិ ។ល។

ការផ្សព្វផ្សាយខ្លឹមសារដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ រាប់ទាំងការញុះញង់ឲ្យមានការប្រកាន់ពូជសាសន៍ ជំនឿសាសនា ឬការមួលបង្កាច់ បរិហាកេរ្តិ៍ និងការជេរប្រមាថជាដើម ក៏នឹងត្រូវរាប់បញ្ចូលក្នុងការចំណោមបទល្មើសនានា

ដែរ។ ក៏ប៉ុន្តែជាគោលការណ៍ ការផ្តន្ទាទោស និងការដាក់ពិន័យចំពោះបទល្មើសទាំងឡាយខាងលើនេះ នឹងត្រូវមានសង្គតិភាពជាមួយបទបញ្ញត្តិច្បាប់នានាជាធរមាន ដូចជា ច្បាប់ស្តីពីរបបសារព័ត៌មាន ក្រមព្រហ្មទណ្ឌ ជាដើម។

**៣-រាជរដ្ឋាភិបាល ជំរុញ និងលើកទឹកចិត្តឲ្យមានការវិនិយោគ និងអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។**

ជាការគួរឲ្យស្តាយដែលថា ក្នុងខណៈដែលសេចក្តីព្រាងច្បាប់នេះមិនទាន់ទាំងបានឈានដល់ដំណាក់កាលនៃការបើកឲ្យមានការពិគ្រោះយោបល់ផង ស្រាប់តែមានមតិមួយចំនួនចោទប្រកាន់រាជរដ្ឋាភិបាលថា មានបំណងត្រួតត្រាប្រព័ន្ធអ៊ីនធឺណិតក្នុងស្រុក និងបំបិទគ្រប់ការរិះគន់ទាំងអស់តាមរយៈអ៊ីនធឺណិត។

តាំងពីអាណត្តិមុនៗ មកម្ល៉េះ រាជរដ្ឋាភិបាលតែងបានប្រកាន់គោលនយោបាយជំរុញការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឲ្យមានលក្ខណៈទំនើប និងប្រកបដោយគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃប្រកួតប្រជែង និងមានសេវាគ្របដណ្តប់ទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់បាន និងទទួលបានផលប្រយោជន៍គ្រប់ៗ គ្នាពីសេវានេះ។

ការរីកចំរើនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ នៃវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៅកម្ពុជា មិនមែនជាការចៃដន្យនោះទេ។ សព្វថ្ងៃនេះ កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ៣ ក្នុងចំណោមប្រទេសអាស៊ានលើអត្រានៃអ្នកជាវស៊ីមកាត (Sim Card) ទូរស័ព្ទចល័ត (139%) ឯ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតបានហក់ពី ៣២០.០០០ នាក់ក្នុងឆ្នាំ២០១០ មកដល់ ៥.០៧៤.៦០០ នាក់ ក្នុងខែកុម្ភៈ ឆ្នាំ២០១៥ គឺកើនឡើងដល់ទៅជិត ១៦ ដង។ បច្ចេកវិទ្យាថ្មី មាន 4G ជាដើម កំពុងត្រូវបានបញ្ចូលក្នុងទីផ្សារ ហើយបន្ថែមពីលើបណ្តាញខ្សែកាប្លិ៍អុបទិច ដែលមានប្រវែងជាង ២ម៉ឺន គីឡូម៉ែត្រ ក្នុងទូទាំងប្រទេស កម្ពុជានឹងត្រូវតភ្ជាប់ដោយខ្សែកាប្លិ៍នៅបាតសមុទ្រដែលនឹងអនុញ្ញាតឲ្យសេវាអ៊ីនធឺណិតរឹតតែលឿន និងរឹតតែខ្លាំងថែមទៀត។ នេះគឺដោយសារនយោបាយជំរុញលើកទឹកចិត្តអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជានិយាយជារួម និងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍និយាយដោយឡែក ដែលទើបបានអនុមតិកាលពីឆ្នាំ២០១៤ថ្មីៗនេះ នូវផែនការមេស្តីពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់កម្ពុជាឆ្នាំ២០២០ ដែលមានអាទិភាពសំខាន់ក្នុងការជំរុញសេវាអេឡិចត្រូនិក (ឬអ៊ី-សេវា - e-service) មានដូចជា អ៊ី-រដ្ឋាភិបាល, អ៊ី-ពាណិជ្ជកម្ម, អ៊ី-អប់រំ, និងអ៊ី-ទេសចរណ៍។ ដំណើរឆ្ពោះទៅកាន់ការធ្វើសុខដុមនីយកម្មប្រេកង់ស៍ 700 MHz សម្រាប់ការផ្តល់សេវាអ៊ីនធឺណិតល្បឿនលឿនចល័ត (mobile broadband) ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត គឺជាការខិតខំមួយទៀត ដើម្បីពង្រីកនូវមធ្យោបាយទទួល និងចែករំលែកព័ត៌មាន និងទិន្នន័យ។

<u>**សរុបសេចក្តីមក**</u> ច្បាប់នេះត្រូវបានព្រាងឡើងដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់គ្រប់តួអង្គទាំងអស់របស់សង្គមជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្ម និងបទល្មើសទាំងឡាយតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងខណៈពេលដែលប្រទេសជាតិ កំពុងឈានចូលក្នុងសករាជសេដ្ឋកិច្ចឌីជីថល (digital)។ ច្បាប់នេះក៏នឹងផ្អែកលើបទពិសោធន៍ល្អៗ និងឧត្តមានុវត្តន៍របស់ប្រទេសនានាក្នុងតំបន់ ព្រមទាំងជានាជោគជ័យរបស់កម្ពុជាក្នុងការធ្វើសមាហរណកម្មចូលក្នុងសហគមន៍អាស៊ានចាប់ពីដើមឆ្នាំ២០១៦ខាងមុខតទៅ។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ យល់ថាវាជាការឆាប់ពេកក្នុងការជជែកដេញដោល និងវិនិច្ឆ័យលើសេចក្តីព្រាងមួយដែលស្ថិតក្នុងដំណាក់កាលនៃការផ្តុំឯកសារបញ្ចូលគ្នានៅឡើយ ប្រៀបបាននឹងការភ្លក់សម្លមួយដែលមិនទាន់ទាំងបង់គ្រឿងគ្រាប់នៅឡើយផង។ ការវិនិច្ឆ័យតាមរបៀបនេះ ជាការផ្ទុយស្រឡះទៅនឹងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការពង្រីកមធ្យោបាយរបស់ប្រជាពលរដ្ឋក្នុងការទទួល និងការចែករំលែកព័ត៌មាន ចំណេះដឹង និងទស្សនៈ។

**រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥**